Employment Plus

Parent Pathways
An Australian Government Initiative



# ដំណើរជីវិតរបស់អ្នក ផ្លូវដើររបស់អ្នក

## ត្រៀមខ្លួនជាស្រេចក្នុងការចាត់វិធានការបន្ទាប់ ប៉ុន្តែមិនដឹងកន្លែងត្រូវចាប់ផ្តើមឬ? យើងអាចជួយអ្នកបាន។

វាកើតឡើងក្នុងមួយពព្រិចភ្នែក – មួយនាទី កូនរបស់អ្នកក្លាយជាការងារពេញម៉ោងរបស់អ្នក ប៉ុន្តែមុននឹងអ្នកដឹងខ្លួន ពួកគេបានទៅសាលាហើយ។ ហើយខណៈពេលដែលពេលវេលាដែលអ្នកចំណាយដើម្បីចិញ្ចឹមកូនបង្កើនតិចនិចចិញ្ចឹមជីវិត គ្រប់គ្រងពេលវេលា និងជំនាញចរចារបស់អ្នកក៏ដោយ ពេលវេលាគ្មានការងារធ្វើអាចធ្វើឲ្យអ្នកមានអារម្មណ៍ភ័យបន្តិចនៅពេលដល់ពេលសម្រេចចិត្តថាតើអ្នកត្រូវធ្វើអ្វីបន្ទាប់។

ដោយមានជំនួយពីអ្នកណែនាំដែលមានសមត្ថភាព អ្នកអាចទទួលបានការគាំទ្រដែលអាចបត់បែនបាន ដើម្បីជួយសម្រេចគោលដៅផ្ទាល់ខ្លួន គោលដៅការសិក្សា ឬគោលដៅការងារ។



# យើងអាចជួយអ្នកដល់គោលដៅ

## តើ Parent Pathways ជាកម្មវិធីអ្វី?

Parent Pathways គឺជាសេវាកម្មស្ម័គ្រចិត្តដែលផ្តល់ការគាំទ្រផ្ទាល់ខ្លួន និងហិរញ្ញវត្ថុដល់ឪពុកម្តាយដែលមានសិទ្ធិ និងអ្នកមើលថែទាំកុមារតូចៗ ដើម្បីជួយពួកគេឱ្យរកឃើញនូវអ្វីដែលជាគោលដៅបន្ទាប់ក្នុងដំណើរជីវិតរបស់ពួកគេ។

កម្មវិធីនេះផ្តោតលើតម្រូវការបុគ្គលរបស់ឪពុកម្តាយដែលកំពុងពិចារណាជំហានបន្ទាប់របស់ពួកគេ ថាតើវាជាការបណ្តុះបណ្តាល ឬការអប់រំ ឬការចូលបម្រើការងារវិញ។ ដោយមានជំនួយពីអ្នកណែនាំដែលមានសមត្ថភាព ឪពុកម្តាយដែលមានសិទ្ធិនិងអ្នកថែទាំអាចទទួលបានការគាំទ្រដែលអាចបត់បែនបានដើម្បីកំណត់ និងសម្រេចបាននូវគោលដៅការសិក្សា និងគោលដៅអាជីពរបស់ពួកគេ និងរក្សាតុល្យភាពគោលដៅទាំងនេះជាមួយទំនួលខុសត្រូវលើគ្រួសាររបស់ពួកគេ។

## តើអ្នកណាមានសិទ្ធិទទួលបាន?

សេវាកម្មនេះគឺសម្រាប់ឪពុកម្តាយ និងអ្នកថែទាំដែល៖

- មានកូនអាយុក្រោម ៦ ឆ្នាំ
- គ្មានការងារដែលមានប្រាក់ខែទេ
- រស់នៅក្នុងតំបន់មិនឆ្ងាយ

ការទទួលបានការទូទាត់មួយក្នុងចំណោមការទូទាត់ខាងក្រោម៖

- ការទូទាត់សម្រាប់ការចិញ្ចឹមកូន (Parenting Payment)
- ការទូទាត់សម្រាប់អ្នកថែទាំ (Carer Payment)
- អត្ថប្រយោជន៍ពិសេស (Special Benefit)

សិទ្ធិទទួលបានរួមមានអ្នកដែលមិនទទួលបានការបង់ប្រាក់របស់ Centrelink និង៖

- អាយុក្រោម ២២ ឆ្នាំ
- អ្នកឈប់រៀនមុនកាលកំណត់ (ឪពុកម្តាយដែលមិនមានសញ្ញាបត្រសម្រាប់ការអប់រំ ១២ ឆ្នាំ)
- ឪពុកម្តាយឬអ្នកថែទាំជាជនជាតិទីមួយ (ជនជាតិដើម)

**ឪពុកម្តាយឬអ្នកថែទាំដែលចូលរួមមានជម្រើសក្នុងការចាកចេញ សម្រាក ឬត្រលប់ទៅធ្វើការវិញនៅពេលណាដែលពួកគេជ្រើសរើស។**



# វិធីសាស្ត្រដែលយើងជួយ

## វិធីសាស្ត្រមួយចំនួនដែលសេវា Parent Pathways ជួយអ្នក៖

- កំណត់គោលដៅអប់រំ និងអាជីព
- បង្កើតផែនការសកម្មភាព
- កាត់បន្ថយគម្លាតជំនាញ
- កសាងទំនុកចិត្ត
- រក្សាតុល្យភាពការងារ និងការចិញ្ចឹមកូន
- ចូលប្រើសេវាកម្ម និងសកម្មភាពក្នុងមូលដ្ឋាន

ឪពុកម្តាយ ឬអ្នកថែទាំនឹងជួបជាមួយអ្នកណែនាំ Employment Plus របស់ពួកគេជាទៀងទាត់។ យើងនឹងនៅជាមួយអ្នកដើម្បីជួយអ្នកបំពេញសកម្មភាពការងារ ឬការអប់រំបន្ថែមទៀត។ យើងជាផ្នែកមួយនៃសហគមន៍របស់អ្នក ហើយនឹងតែងតែនៅចាំជួយ ណែនាំ គាំទ្រ និងដោះស្រាយកង្វល់របស់អ្នក។

## សេវាកម្មរបស់យើង៖

- កម្មវិធីភាសា និងអក្ខរកម្ម
- ការណែនាំអំពីអាជីព
- ជំនួយរកកន្លែងថែទាំកុមារ
- ជំនួយហិរញ្ញវត្ថុសម្រាប់ការបណ្តុះបណ្តាល
- ការបញ្ជូនបន្តទៅទទួលសេវាកម្មគ្រួសារ
- វគ្គខ្លីៗ និងវគ្គបណ្តុះបណ្តាល

លើសពីនេះ អ្នកចូលរួមអាចចូលទៅកាន់កម្មវិធីជំនួយ និងសេវាកម្មផ្សេងៗដែលផ្តល់ដោយ The Salvation Army ដូចជា Moneycare (ការប្រឹក្សាផ្នែកហិរញ្ញវត្ថុ) ការគាំទ្រការស្តារនីតិសម្បទាផ្តាច់គ្រឿងស្រវឹង និងគ្រឿងញៀន និងច្រើនទៀត – ជាអត្ថប្រយោជន៍មួយទៀតនៃការធ្វើការជាមួយ Employment Plus។

## បណ្ណចូលរួម

នៅពេលអ្នកចូលរួមជាមួយកម្មវិធី Parent Pathways ឥឡូវនេះ Employment Plus អាចផ្តល់ជូនបណ្ណគាំទ្រការចូលរួមបន្ទាប់ពីបានចូលរួមការណាត់ជួបទល់មុខគ្នា។
ប័ណ្ណគាំទ្រការចូលរួមត្រូវបានបង្កើតឡើងដើម្បីជួយទប់ទល់ការឡើងថ្លៃប្រេងឥន្ធនៈ គ្រឿងឧបភោគបរិភោគ និងសម្លៀកបំពាក់។ ក្នុងអំឡុងពេលណាត់ជួបរបស់អ្នក យើងនឹងពិភាក្សាអំពីចំណូលចិត្តផ្ទាល់ខ្លួនរបស់អ្នក និងប្រភេទនៃបណ្ណដែលនឹងផ្តល់អត្ថប្រយោជន៍ដ៏អស្ចារ្យបំផុតសម្រាប់អ្នក។

| ជំនួយការចូលរួមដំបូង - បណ្ណទឹកប្រាក់ $១០០ | ជំនួយការចូលរួមបន្ត - បណ្ណទឹកប្រាក់ $៥០ |
|---|---|
| ផ្តល់ជូនដល់អ្នកចូលរួមថ្មីដែលចាប់ផ្តើមនៅក្នុងកម្មវិធីបន្ទាប់ពីបានចូលរួមការណាត់ជួបផ្ទាល់ជាលើកដំបូង។ | ផ្តល់ជូនដល់អ្នកចូលរួមចាស់នៅក្នុងកម្មវិធីដែលចូលរួមការណាត់ជួបផ្ទាល់ដែលកំពុងបន្ត។ |
| អ្នកចូលរួមម្នាក់ទទួលបានទឹកប្រាក់រហូតដល់ $២៥០ ក្នុងបណ្ណគាំទ្រការចូលរួម។ | |

**សួរអ្នកណែនាំ Employment Plus របស់អ្នកសម្រាប់ព័ត៌មានបន្ថែម ឬហៅទូរសព្ទមកយើងតាមលេខ ១៣៦ ១២៣។**

The Salvation Army Employment Plus

Parent Pathways
An Australian Government Initiative

# អំពីយើង

ក្នុងនាមជាអ្នកផ្តល់សេវារកការងារដ៏ធំបំផុតនៅក្នុងប្រទេសអូស្ត្រាលី The Salvation Army Employment Plus បាននិងកំពុងភ្ជាប់ទំនាក់ទំនងអ្នកស្វែងរកការងារជាមួយនិយោជកអស់រយៈពេលជាង ២០ ឆ្នាំមកហើយ។ តាមពិតទៅ យើងបានដាក់មនុស្សជាងកន្លះលាននាក់ឱ្យធ្វើការងារនៅក្នុងអាជីវកម្មជាង ២០០,០០០ កន្លែង។

យើងផ្តល់ជូនអ្នកស្វែងរកការងាររបស់យើងនូវការបណ្តុះបណ្តាលជំនាញ និងសេវាកម្មគាំទ្រជាច្រើន ដើម្បីជួយពួកគេស្វែងរកការងារដែលមានន័យក្នុងជីវិត។

ក្នុងនាមជាអង្គការមិនស្វែងរកប្រាក់ចំណេញ អតិរេកណាមួយដែលយើងបង្កើតគឺត្រូវបានបញ្ជូនត្រលប់ទៅកម្មវិធីសង្គមកិច្ចរបស់ The Salvation Army – ការផ្តល់ជំនួយដល់ជនអនាថា ជនរងគ្រោះដោយគ្រោះមហន្តរាយ និងជនណាម្នាក់ដែលត្រូវការជំនួយ។

ដើម្បីស្វែងយល់បន្ថែមអំពីទីតាំងរបស់យើង ឬព័ត៌មានផ្សេងទៀត សូមចូលទៅកាន់គេហទំព័រ៖

**www.employmentplus.com.au/job-seeker-programs/parent-pathways**

ឥឡូវនេះ យើងកំពុងផ្តល់ជូនកម្មវិធី Parent Pathways នៅ **៥៤ ទីតាំង** ទូទាំង៖



ញូវសៅវែល



អូស្ត្រាលីខាងត្បូង



វិចតូរីយ៉ា

សហគមន៍ និងបណ្តាញតភ្ជាប់គឺជាចំណុចគោលនៃសិល្បៈរបស់ Zona Kelly ក្នុងការឆ្លុះបញ្ចាំងអំពីមរតក Gumbangeri និង Worimi របស់នាង។

វិចិត្រករជនជាតិដើម Zona Kelly មកពី Armidale, NSW។



## ត្រូវការជំនួយទេ?
## យើងប្រចាំការនៅទីនេះ ដើម្បីជួយ

☎ 136 123

www.employmentplus.com.au